កម្មវិធីប្រាក់អាហារូបត្ថម្ភរបស់
រដ្ឋវ៉ាស៊ីនតោន



# ទិដ្ឋភាពទូទៅ

Washington State
Department of Social
& Health Services

*Transforming lives*



## ប្រាក់អាហារូបត្ថម្ភ គឺសំខាន់

កូនៗត្រូវការប្រាក់ឧបត្ថម្ភពីទាំងឪពុក និងម្ដាយ។ នៅពេលដែល ឪពុក/ម្ដាយណាម្នាក់មិនរស់នៅជាមួយកូន ប្រាក់អាហារូបត្ថម្ភ គឺជាប្រាក់ដែលត្រូវទូទាត់ដើម្បីផ្តល់ជូននូវតម្រូវការមូលដ្ឋានរបស់កូន។

- តម្រូវការមូលដ្ឋានរបស់កូនរួមមានចំណីអាហារ ទីជម្រក និងសម្លៀកបំពាក់
- ក៏អាចរួមបញ្ចូលសោហ៊ុយលើការថែទាំកុមារនៅពេលថ្ងៃ និងការធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្រផងដែរ។
- ប្រាក់អាហារូបត្ថម្ភគឺលើសពីអំណោយនៃពេលវេលា ក្តីស្រឡាញ់ និងការគាំទ្រផ្នែកផ្លូវចិត្តរបស់ឪពុក/ម្ដាយណាម្នាក់
- ថែទាំតម្រូវការរបស់កូនៗផ្តល់ជូនពួកគេនូវជីវិតដែលមាន សុខភាពល្អ និងមានសុវត្ថិភាពជាងមុន
- យើងមិនធានាចំពោះការប្រមូល ឬការទូទាត់ប្រាក់អាហារូបត្ថម្ភ ឡើយ

## ផ្នែកប្រាក់អាហារូបត្ថម្ភ

ក្រសួងសេវាសង្គម និងសេវាសុខាភិបាល ផ្នែកប្រាក់អាហារូបត្ថម្ភ (DCS) ប្រមូលប្រាក់អាហារូបត្ថម្ភសម្រាប់កូនៗដែលមានឪពុក/ ម្ដាយម្នាក់ ឬឪពុក និងម្ដាយរស់នៅក្រៅផ្ទះ ដែលរួមបញ្ចូលទាំង អ្នកដែលទទួលបានជំនួយសាធារណៈផងដែរ។

ឪពុកម្ដាយ និងអ្នកថែទាំអាចស្នើសុំ DCS ឲ្យជួយប្រមូល ប្រាក់អាហារូបត្ថម្ភ និងអនុវត្តការធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្រ។

ប្រសិនបើអ្នកមិនទាន់ទទួលបានដីកាសម្រាប់ប្រាក់អាហារូបត្ថម្ភ ទេនោះ DCS អាចបង្កើតដីកាប្រាក់អាហារូបត្ថម្ភផ្នែករដ្ឋបាល មួយបាន។ DCS ក៏អាចសំដៅដល់ករណីនេះសម្រាប់ការបង្កើតបិតុភាពបានផងដែរ។

សម្រាប់ព័ត៌មានបន្ថែមអំពី DCS ៖

- សូមហៅទូរស័ព្ទមកកាន់យើងតាមរយៈលេខ 800-457-6202
- ឬចូលទៅកាន់វែបសាយត៍របស់យើងតាមរយៈ www.childsupportonline.wa.gov

## DCS អាចជួយដល់អ្នក...

- ឲ្យទទួលបានដីកាប្រាក់អាហារូបត្ថម្ភសម្រាប់កូនៗរបស់អ្នក
- ក្នុងការបង្កើតបិតុភាព
- ក្នុងការប្រមូលប្រាក់អាហារូបត្ថម្ភបច្ចុប្បន្ន និងនៅពេលក្រោយ
- អនុវត្តការធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្រ
- កែប្រែដីកាប្រាក់អាហារូបត្ថម្ភរបស់អ្នក
- ធ្វើការជាមួយរដ្ឋផ្សេងទៀតដើម្បីប្រមូលប្រាក់ឧបត្ថម្ភតាងនាមឲ្យអ្នក

## DCS មិនអាចជួយអ្នកបានទេចំពោះ...

- វិវាទសិទ្ធិចិញ្ចឹមបីបាច់ ឬសួរសុខទុក្ខកូន
- ការអនុវត្តការដោះស្រាយទ្រព្យសម្បត្តិសហគម
- ប្រមូលថ្លៃមេធាវី
- បំណុលដទៃទៀតដែលមិនពាក់ព័ន្ធនឹងប្រាក់អាហារូបត្ថម្ភ

## ការដាក់ពាក្យស្នើសុំសេវា DCS

ឪពុកម្ដាយ ឬអ្នកថែទាំអាចដោនឡូតទម្រង់បែបបទនានា តាមរយៈ ៖

www.childsupportonline.wa.gov

*(ចុចលើទម្រង់បែបបទផ្នែកប្រាក់អាហារូបត្ថម្ភ)*

- ឬហៅទូរស័ព្ទទៅកាន់ -

800-442-KIDS (800-442-5437)

ដើម្បីស្នើសុំពាក្យស្នើសុំមួយច្បាប់។

ផ្ញើពាក្យស្នើសុំដែលបានបំពេញរួចតាមប្រៃសណីយ៍ទៅកាន់ ៖

DCS
PO Box 11520
Tacoma, WA 98411

ឪពុកម្ដាយ ឬអ្នកថែទាំដែលទទួលបានជំនួយសាធារណៈមិន ចាំបាច់មានពាក្យស្នើសុំឡើយ ពីព្រោះផ្នែកសេវាសហគមផ្ដល់ព័ត៌មានចាំបាច់នានាជូន DCS។

## ជំនួយសាធារណៈ

វាមានការលំបាកសម្រាប់ឪពុក/ម្ដាយ ឬអ្នកថែទាំណាម្នាក់ក្នុង ការបំពេញទំនួលខុសត្រូវពេញលេញចំពោះរាល់តម្រូវការទាំងអស់របស់កូន។ ពេលខ្លះឪពុកម្ដាយ និងអ្នកថែទាំត្រូវតែទទួលបានជំនួយពីអ្នកជាប់ពន្ធទាំងឡាយតាមរយៈជំនួយ សាធារណៈជាសាច់ប្រាក់ដើម្បីទូទាត់ប្រាក់សម្រាប់តម្រូវការទីលំនៅ ចំណីអាហារ និងតម្រូវការផ្នែកវេជ្ជសាស្ត្ររបស់កូន។ ជំនួយនេះត្រូវបានស្គាល់ថាជាជំនួយបណ្ដោះអាសន្នសម្រាប់គ្រួសារដែលមានតម្រូវការ (TANF)។

- ខណៈពេលដែលឪពុក/ម្ដាយ ឬអ្នកថែទាំណាម្នាក់ទទួលបាន ជំនួយសាធារណៈសម្រាប់កូនម្នាក់នៅក្នុងផ្ទះរបស់ពួកគេ ឬដែល ស្ថិតក្រោមការចិញ្ចឹមថែទាំនោះ រដ្ឋរក្សាទុកប្រាក់អាហារូបត្ថម្ភដែលប្រមូលបានណាមួយ។
- នៅពេលដែលគ្រួសារលែងត្រូវការជំនួយសាធារណៈទៀតហើយ នោះ DCS ប្រមូលប្រាក់អាហារូបត្ថម្ភ និងផ្ញើវាទៅកាន់ឪពុក/ ម្ដាយ ឬអ្នកថែទាំ។

- រដ្ឋអាចរក្សាទុកការទូទាត់ប្រាក់អាហារូបត្ថម្ភមួយចំនួនបាន នៅពេលដែលគ្រួសារនោះលែងទទួលបានជំនួយសាធារណៈបន្តទៀតហើយ។

សម្រាប់ព័ត៌មានបន្ថែមអំពីជំនួយសាធារណៈ សូមហៅទូរស័ព្ទទៅកាន់ផ្នែកសេវាសហគមតាមរយៈលេខ 800-865-7801។

ឬចូលទៅកាន់វែបសាយត៍ www.washingtonconnection.org ដើម្បីដាក់ពាក្យស្នើសុំបន្តសុពលភាព ឬរាយការណ៍អំពីការកែប្រែណាមួយ។

## បិតុភាព



ឪពុកម្តាយដែលមិនទាន់បានរៀបអាពាហ៍ពិពាហ៍អាចបង្កើត បិតុភាព (ភាពជាឪពុក) នៅពេលដែលម្តាយនិងឪពុកយល់ព្រម ថាគាត់គឺជាឪពុក ហើយពួកគេចុះហត្ថលេខានៅលើលិខិតទទួលស្គាល់បិតុភាព។ DCS ក៏ផ្តល់ជូនន្ទូវការធ្វើតេស្តសេនេទិចដើម្បីកំណត់ភាពជាឪពុកនៅក្នុងករណីមួយចំនួនផងដែរ។ ករណីផ្សេងទៀតត្រូវបានបញ្ជូនទៅអនុវត្តចំណាត់ការនៅតុលាការកំពូល។

ការបង្កើតបិតុភាពអាចនាំឲ្យមានដីកាដោះស្រាយកាតព្វកិច្ច ប្រាក់អាហារូបត្ថម្ភ។ វាក៏អាចជួយដល់កូនៗឲ្យទទួលបានធានារ៉ាប់រងសុខភាព ផលប្រយោជន៍របស់អតីតយុទ្ធជន ឬ ផលប្រយោជន៍សន្តិសុខសង្គម។

**មានវិធីចំនួនបីក្នុងការបង្កើតបិតុភាពដោយស្របច្បាប់ ៖**

- ការរៀបអាពាហ៍ពិពាហ៍មុនកំណើតកូន
- ចុះហត្ថលេខាលើទម្រង់បែបបទស្របច្បាប់ដែលហៅថាលិខិតទទួលស្គាល់បិតុភាព និងតម្កល់ទុកនៅក្រសួងសុខាភិបាល។ សំបុត្រកំណើតនឹងដាក់ឈ្មោះឪពុក ប្រសិនបើទាំងឪពុក និងម្តាយយល់ព្រមចុះហត្ថលេខាលើទម្រង់បែបបទនោះ។
- ទទួលបានដីកាតុលាការ។

**សម្រាប់ព័ត៌មានបន្ថែម ៖**

- សូមហៅទូរស័ព្ទទៅកាន់ 1-800-442-5437
- ឬចូលទៅកាន់វែបសាយត៍ការបង្កើតបិតុភាពរបស់យើងតាមរយៈ:
  www.childsupportonline.wa.gov
  *(ចុចលើការបង្កើតបិតុភាព)*

## ដីកាតុលាការ

នៅវ៉ាស៊ីនតោន តុលាការកំពូល និងតុលាការកុលសម្ព័ន្ធបង្កើត ដីកានានា និងសម្រេចចិត្តថាតើអ្នកណាគួរទូទាត់ ប្រាក់អាហារូបត្ថម្ភ។ ដីកាតុលាការអាចជាដីកាសម្រាប់ការលែងលះ សិទ្ធិចិញ្ចឹមបីបាច់ បិតុភាព និង/ឬបញ្ហាផ្សេងទៀត ដែលពាក់ព័ន្ធនឹងប្រាក់អាហារូបត្ថម្ភ។ មានតែតុលាការប៉ុណ្ណោះ ដែលអាចធ្វើការកែប្រែដីកាតុលាការបាន។

DCS មិនអាចកែប្រែពាក្យពេចន៍នៅក្នុងដីកាតុលាការបាន ឡើយ។ ច្បាប់រដ្ឋតម្រូវឲ្យ DCS អនុវត្តតាមដីកាតុលាការតាមអ្វី ដែលបានសរសេរគ្រប់យ៉ាង។ នៅពេលដែល DCS បង្កើតដីកា ប្រាក់អាហារូបត្ថម្ភ យើងរួមបញ្ចូលបញ្ញត្តិស្តីពីប្រាក់ឧបត្ថម្ភផ្នែក វេជ្ជសាស្ត្រដែលតម្រូវឲ្យទាំងឪពុក និងម្ដាយផ្ដល់ការធានារ៉ាប់រង ផ្នែកវេជ្ជសាស្ត្រ នៅពេលដែលអាចរ៉ែស្វែងរកបានតាមរយៈ និយោជក ឬសហជីព។

## បំណុលដែលនៅជំពាក់

- DCS និងតុលាការកំណត់ការទូទាត់ប្រាក់អាហារូបត្ថម្ភប្រចាំខែ ដោយប្រើប្រាស់កាលវិភាគប្រាក់អាហារូបត្ថម្ភរបស់ រដ្ឋវ៉ាស៊ីនតោន និងស្របតាមសមត្ថភាពក្នុងការទូទាត់ប្រាក់របស់ ឪពុក/ម្ដាយ។
- ប្រាក់អាហារូបត្ថម្ភដែលមិនបានទូទាត់នឹងក្លាយជាបំណុលដែលហៅថាបំណុលដែលនៅជំពាក់។
- ប្រាក់ដែលនៅជំពាក់ឪពុកម្ដាយដែលមានសិទ្ធិចិញ្ចឹមបីបាច់ សម្រាប់ប្រាក់អាហារូបត្ថមកាលពីមុន ឬជំពាក់ DCS សម្រាប់ជំនួយ TANF ដែលបានផ្ដល់ជូនកុមារគឺជាបំណុលដែលនៅជំពាក់។

## ការធ្វើឲ្យដីកាប្រាក់អាហារូបត្ថម្ភមានការប្រែប្រួល (ការកែប្រែ)

ប្រសិនបើអ្នកមានបំណងឲ្យ DCS ត្រួតពិនិត្យដីកាប្រាក់ឧបត្ថម្ភ របស់អ្នកឡើងវិញ សូមហៅទូរស័ព្ទទៅកាន់ DCS និងស្នើសុំការ ត្រួតពិនិត្យការកែប្រែឡើងវិញ។ ឪពុកម្ដាយក៏អាចកែប្រែដីកា ប្រាក់អាហារូបត្ថម្ភរបស់ពួកគេដោយផ្ទាល់ ឬដោយមានជំនួយពី អ្នកជួយសម្រួលច្បាប់គ្រួសារ ឬមេធាវីស្របច្បាប់បានផងដែរ។ អ្នកជួយសម្រួលអាចមានលទ្ធភាពក្នុងការជួយដល់ដំណើរការ កែប្រែតាងនាមឲ្យខ្លួនឯង (សម្រាប់ខ្លួនរបស់អ្នក)។ នេះមានន័យ ថា ការធ្វើដំណើរទៅកាន់តុលាការដោយខ្លួនអ្នកផ្ទាល់ដោយ មិនចាំបាច់មានជំនួយពីមេធាវីនោះទេ។ ពេលខ្លះការដំណើរការ រឿងក្តីតាងនាមឲ្យខ្លួនឯងគឺជាវិធីដ៏លឿនក្នុងការកែប្រែដីកា ប្រាក់អាហារូបត្ថម្ភ។

ដើម្បីស្វែងរកអ្នកជួយសម្រួលនៅក្នុងការិយាល័យក្រឡាបញ្ជីនៃ ខោនធីរបស់អ្នក សូមហៅទូរស័ព្ទទៅកាន់លេខ 800-933-6772.

- ឬចូលទៅកាន់ www.courts.wa.gov ឬ www.mrsc.org។

## ការទូទាត់ប្រាក់ជូន DCS

ដីកាមួយចំនួនអនុញ្ញាតឲ្យអ្នកទូទាត់ប្រាក់ផ្ញើប្រាក់ដែលត្រូវទូទាត់ ទៅកាន់ឪពុក/ម្ដាយដែលមានសិទ្ធិចិញ្ចឹមបីបាច់ដោយផ្ទាល់។ ដីកាផ្សេងទៀតអនុញ្ញាតឲ្យអ្នកទូទាត់ប្រាក់ផ្ញើប្រាក់ដែលត្រូវទូទាត់ ទៅកាន់ DCS តាមរយៈមូលប្បទានបត្រផ្ទាល់ខ្លួន នៅលើវែប ឬតាមរយៈការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិច (EFT)។ សម្រាប់ព័ត៌មានបន្ថែមអំពី EFT និងសម្រាប់ព័ត៌មានបន្ថែមអំពី EFT និងការទូទាត់ប្រាក់តាមវែប សូមហៅទូរស័ព្ទទៅកាន់លេខ 800-468-7422 ឬចូលទៅមើលវែបសាយត៍របស់ DCS តាមរយៈ www.childsupportonline.wa.gov។

ដីកាប្រាក់ឧបត្ថម្ភភាគច្រើនផ្ដល់ជូនសម្រាប់ការកាត់ទុកប្រាក់ចំណូល ដែលមានន័យថានិយោជកត្រូវបានតម្រូវឲកាត់ទុក ប្រាក់ឧបត្ថម្ភពីប្រាក់ចំណូលសុទ្ធរបស់ឪពុក/ម្ដាយដែលគ្មានសិទ្ធិចិញ្ចឹមបីបាច់ ដែលជាចំនួនទឹកប្រាក់ដែលនៅសល់បន្ទាប់ពីការកាត់ប្រាក់ដែលត្រូវបានតម្រូវដោយស្របច្បាប់ត្រូវបានធ្វើឡើង និងផ្ញើប្រាក់នោះទៅកាន់ការិយាល័យចុះបញ្ជីប្រាក់ឧបត្ថម្ភរបស់រដ្ឋវ៉ាស៊ីនតោន (WSSR)។ នៅក្នុងឧទាហរណ៍ភាគច្រើន DCS អាចអនុវត្តវិធានការកាត់ទុកទោះបីជាឪពុក/ម្ដាយដែលគ្មានសិទ្ធិចិញ្ចឹមបីបាច់មិនស្ថិតនៅពីក្រោយការទូទាត់ប្រាក់ក៏ដោយ។

ផ្ញើមូលប្បទានបត្រ ឬដីកាបង្គាប់ឲ្យទូទាត់ប្រាក់ទៅកាន់ ៖

**WSSR**
**PO Box 45868**
**Olympia, WA 98504-5868**

*ដើម្បីធានាទាំពោះការដំណើរការយ៉ាងត្រឹមត្រូវ សូមប្រាកដថា ឈ្មោះ និងលេខសន្តិសុខសង្គម របស់អ្នកត្រូវបានកត់សម្គាល់យ៉ាងច្បាស់លាស់នៅលើការទូទាត់ប្រាក់របស់អ្នក*

## ការទូទាត់ប្រាក់ជូនឪពុកម្តាយ និងអ្នកថែទាំ

ឪពុកម្តាយដែលមានសិទ្ធិចិញ្ចឹមបីបាច់អាចទទួលបានការទូទាត់ប្រាក់អាហារូបត្ថម្ភតាមរយៈ ការដាក់ប្រាក់តម្កល់ដោយផ្ទាល់ ឬ ប័ណ្ណឥណពន្ធទូទាត់ប្រាក់ជាមុន ដែលហៅថាប័ណ្ណ DCS។ វិធីសាស្ត្រទាំងនេះអនុញ្ញាតឲ្យ DCS ដាក់ប្រាក់តម្កល់តាមប្រព័ន្ធអេឡិចត្រូនិច។ ប័ណ្ណ DCS មានរូបសញ្ញាវីសា និងអនុញ្ញាតឲ្យ DCS ដាក់ប្រាក់តម្កល់ ធ្វើដូច្នេះ ម៉ាស៊ីនអេធីអឹម ឬទីតាំងកន្លែងលក់នានា (ដែលទទួលយកវីសាកាត) អាចបញ្ចេញប្រាក់អាហារូបត្ថម្ភបាន។

ការដាក់ប្រាក់តម្កល់ដោយផ្ទាល់ និងទម្រង់បែបបទអនុញ្ញាត សម្រាប់ប័ណ្ណ DCS អាចស្វែងរកបាននៅលើវែបសាយត៍របស់ DCS តាមរយៈ www.childsupportonline.wa.gov *(ចុចលើ ទម្រង់បែបបទផ្នែកប្រាក់អាហារូបត្ថម)* ។ សម្រាប់ ព័ត៌មានបន្ថែម សូមហៅទូរស័ព្ទទៅកាន់លេខ 1-800-468-7422។

## មូលហេតុដែលអាចពន្យារពេលធ្វើសកម្មភាពចំពោះរឿងក្តីរបស់អ្នក

- DCS ត្រូវចំណាយពេលច្រើនដើម្បីទទួលបានដីកាតុលាការពី ក្រឡាបញ្ជីតុលាការកំពូល និងរៀបចំរឿងក្តីណាមួយ
- នៅពេលខ្លះ DCS មិនអាចស្វែងរកឪពុក/ម្តាយដែលគ្មាន សិទ្ធិចិញ្ចឹមបីបាច់ឃើញដើម្បីប្រគល់លិខិតគតិយុត្តិជូន រឹបអូសប្រាក់ឈ្នួល ឬទ្រព្យសកម្មផ្សេងទៀតបាននោះទេ។
- នៅពេលខ្លះ ឪពុក/ម្តាយដែលគ្មានសិទ្ធិចិញ្ចឹមបីបាច់ស្នើសុំបើក សវនាការមួយដើម្បីប្រកួតប្រជែងជាមួយការទូទាត់ប្រាក់អាហារូបត្ថម្ភ ឬបំណុលដែលនៅជំពាក់
- ប្រសិនបើឪពុក/ម្តាយដែលគ្មានសិទ្ធិចិញ្ចឹមបីបាច់កំពុងទទួលបាន ជំនួយសាធារណៈ ឬ គ្មានការងារធ្វើនោះ DCS មិនអាចប្រមូលប្រាក់ឧបត្ថម្ភបាននោះទេ
- ប្រសិនបើឪពុក/ម្តាយដែលមានសិទ្ធិចិញ្ចឹមបីបាច់ឃើញមិនផ្តល់អាសយដ្ឋានបច្ចុប្បន្នទេនោះ ការទូទាត់ប្រាក់អាចត្រូវបានពន្យារពេល។

## ការអនុវត្ត

ច្បាប់រដ្ឋ និងច្បាប់សហព័ន្ធផ្តល់ជូន DCS នូវវិធីសាស្ត្រជាច្រើន ក្នុងការប្រមូលប្រាក់អាហារូបត្ថម្ភ។ យើងហៅវាថា "ការអនុវត្ត" នៅពេលដែលយើងប្រើប្រាស់វិធីសាស្ត្រក្នុងការប្រមូល។ វិធីសាស្ត្រមួយចំនួនដែលយើងប្រើប្រាស់ដើម្បីប្រមូលប្រាក់អាហារូបត្ថម្ភរួមមាន ៖

- រឹបអូសប្រាក់ឈ្នួល និងប្រាក់ចំណូលផ្សេងទៀត ដូចជាផលប្រយោជន៍នៃភាពគ្មានការងារធ្វើ និងផលប្រយោជន៍ នៃការចូលនិវត្តន៍ជាដើម
- ការព្យួរអាជ្ញាប័ណ្ណបើកបរ អាជ្ញាប័ណ្ណនេសាទ អាជ្ញាប័ណ្ណបរបាញ់ និងអាជ្ញាប័ណ្ណផ្សេងទៀត
- ការដកហូត និងការលក់រថយន្ត ទូក និងយានជំនិះផ្សេងទៀត
- រឹបអូសការវិនិយោគ គណនីសន្សំសំចៃ និងគណនីមូលប្បទានបត្រ
- រឹបអូសប្រាក់ចំណូល IRS មរតក និងការឈ្នះឆ្នោត
- ការបដិសេធចំពោះលិខិតឆ្លងដែន

## រដ្ឋផ្សេងទៀត

ច្បាប់រដ្ឋ និងច្បាប់សហព័ន្ធអនុញ្ញាតឲ្យរដ្ឋនានាធ្វើការរួមគ្នានៅ ពេលដែលឪពុកម្តាយរស់នៅក្នុងរដ្ឋផ្សេងគ្នា។ DCS អាចស្នើសុំ រដ្ឋផ្សេងទៀតជួយបង្កើត កែប្រែ និងប្រមូលប្រាក់អាហារូបត្ថម្ភ ហើយរដ្ឋផ្សេងទៀតក៏ស្នើសុំ DCS ឲ្យជួយដល់ពួកគេបានផងដែរ។

ពីព្រោះច្បាប់របស់គ្រប់រដ្ឋទាំងអស់ គឺមិនដូចគ្នានោះទេ វាអាច មានការលំបាកក្នុងការប្រមូលប្រាក់ជាទៀងទាត់នៅពេលដែល រដ្ឋចំនួនពីរ ឬច្រើនធ្វើការលើករណីប្រាក់អាហារូបត្ថម្ភណាមួយ។ នៅពេលដែលករណីនេះកើតឡើង DCS ព្យាយាមស្វែងរក និងរឹបអូសប្រាក់ឈ្នួលនានា។ រដ្ឋមួយចំនួនគិតថ្លៃសេវានានា និងរដ្ឋ មួយចំនួនគិតការប្រាក់លើសមតុល្យបំណុលនៅជំពាក់ ដែលមិនទាន់បានទូទាត់។ រដ្ឋវ៉ាស៊ីនតោនគិតកម្រៃប្រចាំឆ្នាំចំនួន $25.00 ប្រសិនបើអ្នកមិនធ្លាប់ទទួលបានជំនួយបណ្តោះអាសន្ន សម្រាប់គ្រួសារដែលមានតម្រូវការ (TANF), TANF កុលសម្ព័ន្ធ ឬជំនួយសម្រាប់គ្រួសារដែលមានកូនរស់នៅក្នុងបន្ទុក (AFDC) សម្រាប់កូនៗនៅក្នុងគ្រួសារ។ រដ្ឋវ៉ាស៊ីនតោនប្រមូលការប្រាក់ឲ្យរដ្ឋផ្សេងទៀត។

## រឿងក្តីកុលសម្ព័ន្ធ

កុលសម្ព័ន្ធជនជាតិដើមអាមេរិកមួយចំនួនមានកម្មវិធីប្រាក់អាហារូបត្ថម្ភផ្ទាល់ខ្លួនរបស់ពួកគេ។ កុលសម្ព័ន្ធផ្សេងទៀតអាច មានច្បាប់ប្រាក់អាហារូបត្ថម្ភផ្ទាល់ខ្លួនរបស់ពួកគេ និងដំណើរការ បង្កើត និងអនុវត្តប្រាក់អាហារូបត្ថម្ភនៅពេលដែលឪពុក/ម្តាយគឺ ជាសមាជិកមួយរូបរបស់កុលសម្ព័ន្ធ រស់នៅក្នុងទឹកន្លែងសម្រាប់ កុលសម្ព័ន្ធនោះ ឬធ្វើការឲ្យកុលសម្ព័ន្ធនោះ។ DCS ធ្វើការ ជាមួយកុលសម្ព័ន្ធដើម្បីបង្កើត និងអនុវត្តរឿងក្តីប្រាក់ អាហារូបត្ថម្ភនានា។

ហៅទូរស័ព្ទទៅកាន់ DCS សម្រាប់ព័ត៌មានស្តីពី ប្រាក់អាហារូបត្ថម្ភរបស់កុលសម្ព័ន្ធ ឬចូលទៅកាន់វែបសាយត៍ របស់យើងតាមរយៈ www.childsupportonline.wa.gov (*ចុចលើ*ទំនាក់ទំនងរបស់កុលសម្ព័ន្ធ)។

## ទាំងឪពុក និងម្តាយគួរប្រាប់ DCS នៅពេលដែល ៖

- កូនផ្លាស់មករស់នៅក្នុងផ្ទះ ឬផ្លាស់ទៅរស់នៅក្រៅផ្ទះ
- អ្នកផ្លាស់ប្តូរ និងមានអាសយដ្ឋានថ្មីមួយ
- អ្នកប្តូរឈ្មោះរបស់អ្នក
- មានដីកាតុលាការថ្មីមួយ
- អ្នក ឬកូនទទួលបានជំនួយសាធារណ: មានពិការភាព ផ្នែកសន្តិសុខសង្គម (SSD) ឬប្រាក់ចំណូលសន្តិសុខបន្ថែម (SSI)

DCS ទាក់ទងឪពុកម្តាយ និងអ្នកថែទាំទាំងឡាយដើម្បីសាកសួរ ថាតើពួកគេមានព័ត៌មានដើម្បីជួយដល់ការប្រមូលប្រាក់អាហារូបត្ថម្ភដែរឬទេ។ សូមប្រាប់យើងខ្ញុំប្រសិនបើឪពុកម្តាយដែលគ្មានសិទ្ធិចិញ្ចឹមបីបាច់ ៖

- ផ្លាស់ប្តូរការងារ ក្លាយជាគ្មានការងារធ្វើ ឬរងរបួស
- ប្រើប្រាស់ឈ្មោះ និងលេខសន្តិសុខសង្គមផ្សេងទៀត
- កាន់កាប់ជាកម្មសិទ្ធិលើរថយន្ត ផ្ទះ ឬការវិនិយោគ ឬគណនីធនាគារ
- មានគ្រួសារ និងមិត្តភ័ក្តិដែលអាចដឹងព័ត៌មាន
- ជាប់គុក ជាប់ពន្ធនាគារ ឬស្ថិតនៅក្នុងការដោះលែងឲ្យនៅក្រៅឃុំ

## អំពើហិង្សាក្នុងគ្រួសារ

អ្នកអាចទទួលបានជំនួយប្រសិនបើអ្នក ឬកូនរបស់អ្នកមិនស្ថិតនៅក្នុងគ្រោះថ្នាក់។ ការបំពានលើរាងកាយ គឺជាបទឧក្រិដ្ឋ។

- ហៅទូរស័ព្ទទៅកាន់នគរបាល
- ហៅទូរស័ព្ទទៅកាន់ខ្សែទូរស័ព្ទបន្ទាន់ផ្នែកអំពើហិង្សាក្នុងគ្រួសារតាមរយៈលេខ 800-562-6025
- ហៅទូរស័ព្ទទៅកាន់សេវាការពារកុមារ (CPS) តាមរយៈលេខ 800-562-5624 ឬ 866-ENDHARM
- ហៅទូរស័ព្ទទៅកាន់កម្មវិធីរក្សាការសម្ងាត់អាសយដ្ឋាន (ACP) តាមរយៈលេខ 800-822-1065
- ប្រាប់មន្ត្រីអនុវត្តប្រាក់ឧបត្ថម្ភរបស់អ្នក ឬបុគ្គលិកផ្នែកជំនួយ សាធារណៈរបស់អ្នក។ ច្បាប់រដ្ឋតម្រូវឲ្យយើងខ្ញុំធ្វើការរាយការណ៍ ប្រសិនបើយើងខ្ញុំជឿជាក់ថាកុមារណាម្នាក់ គឺជាជនរងគ្រោះនៃការបំពាន ឬការមិនអើពើ។

## ជនពិការ

DCS ផ្តល់ជំនួយសម្រាប់ភាពទន់ខ្សោយផ្នែកស្តាប់។

- ហៅទូរស័ព្ទទៅកាន់ខ្សែទូរស័ព្ទ TDD របស់យើងតាមរយៈលេខ 360-664-5011

យើងក៏អាចរៀបចំភាសាសញ្ញា និងអ្នកបកប្រែផ្ទាល់មាត់ផងដែរ។

- ហៅទូរស័ព្ទមកកាន់យើងខ្ញុំតាមរយៈលេខ 800-820-2363



## យើងដឹងថាអ្នកចង់ថែទាំកូនៗរបស់អ្នក។
## *ឲ្យយើងជួយអ្នក*

| ទីក្រុង | លេខទូរស័ព្ទ | អ៊ីមែល |
|---|---|---|
| **Everett:** | 800-729-7580<br>425-438-4800 | everett-dcs@dshs.wa.gov |
| **Kennewick:** | 800-345-9981<br>509-374-2000 | ken-imail@dshs.wa.gov |
| **Olympia:** | 800-345-9964<br>360-664-6900 | oly-imail@dshs.wa.gov |
| **Seattle:** | 800-526-8658<br>206-341-7000 | seattle-dcs@dshs.wa.gov |
| **Spokane:** | 800-345-9982<br>509-363-5000 | spomail@dshs.wa.gov |
| **Tacoma:** | 800-345-9976<br>253-597-3700 | tacoma-dcs@dshs.wa.gov |
| **Vancouver:** | 800-345-9984<br>360-696-6100 | vancouver-dcs@dshs.wa.gov |
| **Wenatchee:** | 800-535-1113<br>509-886-6800 | wenatchee-dcs@dshs.wa.gov |
| **Yakima:** | 800-441-0859<br>509-249-6000 | yak-imail@dshs.wa.gov |
| **ទីស្នាក់ការកណ្តាល ៖** | 800-457-6202<br>360-664-5000 | dcs-cru@dshs.wa.gov |

Washington State
Department of Social
& Health Services

*Transforming lives*

DSHS 22-583 CA (Rev. 12/15)
Cambodian